**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ ០២៣/០៩ កប/ ស.ជ.ណ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ថ្ងៃឈប់បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារបានជ្រាបថា យោងតាមច្បាប់ស្តីពីការងារ និងប្រកាសរបស់ក្រសួងលេខ ២១៤ កប/ប្រ.ក ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ២០០៨ ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ២០០៩ សូមអស់លោក លោកស្រី អនុញ្ញាតឱ្យកម្មករនិយោជិតទាំងអស់របស់ខ្លួន ឈប់សំរាកដោយមានប្រាក់ឈ្នួលនាឱកាសបុណ្យចូលឆ្នាំខ្មែរខាងមុខនេះក្នុងរយៈពេលបីថ្ងៃ គឺថ្ងៃទី ១៤-១៥ និងថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៩ ។

ក្រសួងសូមបញ្ជាក់ថា ក្នុងករណីចាំបាច់បំផុត ដែលសហគ្រាស គ្រឹះស្ថាន មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបានក្នុឱកាសថ្ងៃឈប់សំរាកបុណ្យចូលឆ្នាំខ្មែរខាងមុខនេះ ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ត្រូវសម្របសម្រួលជាមួយកម្មករនិយោជិតឱ្យមានការស្ម័គចិត្ត ព្រមទាំងបែងចែកឱ្យមានពេលវេលា និងថ្ងៃឈប់សំរាកបុណ្យបានសមស្រប ។

កម្មករ និយោជិតដែលធ្វើការថ្ងៃបុណ្យឈប់សំរាកនេះ មានសិទ្ធិទទួលនូវប្រាក់បំណាច់បន្ថែមដែលមានចំនួនស្មើនឹង ប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

ក្នុងករណីមានលទ្ធភាព ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថាន គួរចាត់តាំងឱ្យមានការលេងល្បែងកំសាន្តនានានៅតាមសហគ្រាស គ្រឹះស្ថានរបស់ខ្លួន ដើម្បីចូលរួមអបអរសាទរពិធីបុណ្យចូលឆ្នាំ និងដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករ និយោជិតដែលបានបំពេញការងារកន្លងមកផង ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមជឿជាក់ថា អស់លោក លោកស្រី ដែលជាម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អត្រឹមត្រូវជាមិនពុំខាន ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

« ដើម្បីជូនជ្រាប »

- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី

« ដើម្បីផ្សព្វផ្សាយ និងអនុវត្ត »

- សមាគមនិយោជក « ដើម្បីជ្រាប និងអនុវត្ត »
- សហព័ន្ធសហជីព « ដើម្បីជ្រាប »
- កាលប្បវត្តិ និងឯកសារ